**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**រដ្ឋបាលជលផល**

លេខ: ......៨៤៤......... ជផ

# សេចក្តីសម្រេច
# ស្តីពី
# គោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការប្រើឱសថវារីសត្វក្នុងវារីវប្បកម្ម

## ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា
## ប្រធានរដ្ឋបាលជលផល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២២/០០៦ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩១២/០០៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញារ៉ូតែដាម ស្តីពីនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុនចំពោះសារធាតុគីមី និងថ្នាំកសិកម្មគ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ

អាសយដ្ឋាន:អាគារលេខ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ប្រអប់សំបុត្រលេខ៥៨២ /Fax: (855) 23 215 470 www.fia.gov.kh
Address #186 Preah Norodom Blvd., Sangkat Tonle Bassac, Khan Chamcar Mon, Phnom Penh capital, Cambodia. P.O.Box 582 /Fax: (855) 23 215 470 www.fia.gov.kh

- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ
- បានឃើញអនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីអនាម័យនៃម្ហូបអាហារសំរាប់មនុស្ស
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកេ្សត្រសាស្រ្តនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ៣៨៦ ប្រក.កសក.ប ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពរបស់រដ្ឋបាលជលផល
- បានឃើញប្រកាសលេខ៦៨១ ប្រក.កសក.ប ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ការិយាល័យនិងមន្ទីរពិសោធន៍ចំណុះនាយកដ្ឋាន និងវិទ្យាស្ថានក្រោមឱវាទរដ្ឋបាលជលផល
- បានឃើញប្រកាសលេខ១១៣ ប្រក.កសក.ប ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ការិយាល័យចំណុះមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍន៍វារីវប្បកម្មសមុទ្រ
- យោងតាមការចាំបាច់របស់រដ្ឋបាលជលផល

## សម្រេច

**ប្រការ ១ .-**

សេចក្តីសម្រេចនេះ កំណត់អំពីគោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការប្រើឱសថវារីសត្វក្នុងវារីវប្បកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅធានាសុវត្ថិភាពម្ហូបអាហារនិងការពារសុខភាពសាធារណៈ ស្របតាមគោលការណ៍ណែនាំនិងស្តង់ដារពាក់ព័ន្ធរបស់គណៈកម្មាធិការកូដិចអន្តរជាតិ (Codex Alimentarius) និងក្រមសុខភាពវារីសត្វរបស់អង្គការសុខភាពសត្វពិភពលោក (WOAH Aquatic Animal Health Code)។

**ប្រការ ២ .-**

សេចក្តីសម្រេចនេះ មានវិសាលភាពអនុវត្តចំពោះកសិដ្ឋានវារីវប្បកម្ម កន្លែងផលិត នាំចូល-នាំចេញ ធ្វើសន្និធិ វេចខ្ចប់ ចែកចាយ លក់ដុំនិងលក់រាយឱសថវារីសត្វ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣ .-**

គោលការណ៍ណែនាំបច្ចេកទេសស្តីពីការប្រើឱសថវារីសត្វក្នុងវារីវប្បកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា មានភ្ជាប់ជាឧបសម្ព័ន្ធ នៃសេចក្តីសម្រេចនេះ។

**ប្រការ ៤ .-**

សេចក្តីសម្រេច ឬបទបញ្ញាទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥ .-**

ប្រធាននាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលនិងនីតិកម្ម ប្រធាននាយកដ្ឋានបច្ចេកវិទ្យាកែច្នៃ និងគុណភាព គ្រប់អង្គភាពក្រោមឱវាទរដ្ឋបាលជលផល ត្រូវសហការផ្សព្វផ្សាយនិងអនុវត្តគោលការណ៍ណែនាំបច្ចេកទេសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ១៣ កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មិនា ឆ្នាំ២០២៤

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

**ពុំ សុថា**

**ចម្លងជូន ៖**
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៥
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ

ភ្ជាប់សេចក្តីសម្រេចលេខៈ ៩៥៥ ដផ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤

# គោលការណ៍ណែនាំបច្ចេកទេស
# សម្រាប់ការប្រើឱសថវារីសត្វក្នុងវារីវប្បកម្ម
# ក្នុងព្រះរាជាណាចក្រកម្ពុជា

---

## មាតិកា


**ពាក្យបំព្រួញ**

**១. សេចក្តីផ្តើម**

**២. គោលបំណង**

**៣. វិសាលភាព**

**៤. ការអនុញ្ញាតនិងហាមឃាត់ការឱសថវារីសត្វ**

៤.១ ឱសថវារីសត្វដែលអនុញ្ញាតឱ្យប្រើក្នុងវារីវប្បកម្ម

៤.២ ឱសថវារីសត្វដែលហាមឃាត់ប្រើក្នុងវារីវប្បកម្ម

៤.៣ ការប្រើឱសថវារីសត្វសម្រាប់ព្យាបាលវារីសត្វ

**៥. ការធ្វើពាណិជ្ជកម្ម**

៥.១ ការធ្វើពាណិជ្ជកម្មឱសថវារីសត្វ

៥.២ ការធ្វើពាណិជ្ជកម្មចំណីវារីសត្វ

៥.៣ ការផ្សព្វផ្សាយពាណិជ្ជកម្មឱសថវារីសត្វ

**៦. ការត្រួតពិនិត្យសំណល់ឱសថវារីសត្វក្នុងវារីសត្វនាំចូល**

**៧. សមត្ថកិច្ច និងការទទួលខុសត្រូវ**

៧.១ អង្គភាពទទួលបន្ទុកមានសមត្ថកិច្ច

៧.២ មន្ត្រីអធិការកិច្ចវារីវប្បកម្ម

៧.៣ ការទទួលខុសត្រូវរបស់មន្ត្រីអធិការកិច្ចវារីវប្បកម្ម

៧.៤ ការទទួលខុសត្រូវរបស់វារីវប្បករ ឬម្ចាស់កសិដ្ឋានវារីវប្បកម្ម

# ពាក្យបំព្រួញ

| | |
|---|---|
| AHD | : Furazolidone metabolite |
| AMOZ | : Furaltadone metabolite |
| AMR | : Antimicrobial Resistance |
| AOZ | : Nitrofurantoin metabolite |
| CSLI | : Clinical Standard Laboratory Institute |
| DMZ | : Dimetridazole |
| GAqP | : Good Aquaculture Practice |
| HMMNI | : Hydroxy Dimetridazole |
| IPZ | : Ipronidazole |
| IPZ-OH | : Hydroxy ipronidazole |
| MNZ | : Metronidazole |
| MNZ-OH | : Hydroxymetronidazole |
| MRL | : Maximum Residue Levels |
| RMR | : Risk Management Review |
| RNZ | : Ronidazole |
| SEM | : Nitrofurazone metabolite |
| WOAH | : World Organization for Animal Health |

## ១. សេចក្ដីផ្ដើម

វារីវប្បកម្ម បាននិងកំពុងមានតួនាទីយ៉ាងសំខាន់ក្នុងប្រទេសកម្ពុជា សម្រាប់ចូលរួមបំពេញនូវតម្រូវការទីផ្សារក្នុងស្រុក និងជំរុញកំណើនសេដ្ឋកិច្ចជាតិ តាមរយៈការនាំចេញផលវារីវប្បកម្ម។ និន្នាការនេះ បានជំរុញឱ្យផ្នែកផលិតកម្មមានការប្រើឱសថវារីសត្វ និងសារធាតុគីមីផ្សេងៗ ជាច្រើននៅក្នុងវារីវប្បកម្ម ក្នុងគោលបំណង ដើម្បីការពារវារីសត្វដែលចិញ្ចឹមកុំឱ្យងាយរងគ្រោះទៅនឹងជំងឺជាច្រើន បញ្ហាសុខភាព និងបង្កើនទិន្នផលផងដែរ។ ការធ្វើវារីវប្បកម្មត្រូវពឹងផ្អែកយ៉ាងខ្លាំងលើការប្រើឱសថវារីសត្វ ដើម្បីទទួលបានផលិតភាពកាន់តែខ្ពស់ តាមរយៈការការពារនឹងជំងឺឆ្លងជាច្រើនដោយសារមេរោគ បាក់តេរី ផ្សិត និងប៉ារ៉ាស៊ីត ប៉ុន្តែការប្រើប្រាស់ឱសថវារីសត្វដែលមិនអាចគ្រប់គ្រងបាន និងមិនសមស្របនឹងជំងឺអាចនាំឱ្យបង្កហានិភ័យចំពោះភាពស៊ាំនឹងមេរោគ ដែលនៅទីបំផុតនឹងប៉ះពាល់ដល់ប្រព័ន្ធផលិតកម្ម និងបរិស្ថានទាំងមូល។

ការការពារការឆ្លងជំងឺនៅក្នុងវារីវប្បកម្ម អាចត្រូវបានធានា តាមរយៈការអនុវត្តគោលការណ៍អនុវត្តវារីវប្បកម្មល្អ (GAqP) ជាពិសេសផ្ដោតលើការគ្រប់គ្រងគុណភាពទឹក គុណភាពចំណី និងការធ្វើអនាម័យឱ្យបានសមស្រប។ ទោះជាយ៉ាងណាក៏ដោយ ឱសថវារីសត្វ និងសារធាតុគីមីផ្សេងៗ ត្រូវបានប្រើជាច្រើនសតវត្សមកហើយ ដែលជាកត្តាគន្លឹះសម្រាប់ទទួលបានជោគជ័យក្នុងសកម្មភាពវារីវប្បកម្ម។ ដូច្នេះ ទាមទារឱ្យមានការគ្រប់គ្រង និងត្រួតពិនិត្យឱ្យបានល្អប្រសើរលើសុខភាពវារីសត្វ គុណភាពទឹក គុណភាពចំណី ការបង្កាត់ ភ្ញាស់ និងការបំប៉នវារីសត្វ ព្រមទាំងការដឹកជញ្ជូន និងការកែច្នៃផលវារីវប្បកម្ម។

ឱសថប្រឆាំងមេរោគ (ឱសថអង់ទីប៊ីយ៉ូទិក) ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងវិស័យផលិតកម្មសត្វ ដោយឡែកចំពោះវារីសត្វ ក៏មានប្រើប្រាស់ឱសថប្រឆាំងមេរោគមួយចំនួនក្នុងវារីវប្បកម្មផងដែរ។ ឱសថទាំងនេះត្រូវបានប្រើប្រាស់ តាមរយៈបញ្ចូលលាយក្នុងចំណី និងខ្លះទៀតតាមរយៈការប្រើប្រាស់ផ្ទាល់។ ទោះជាយ៉ាងណាក៏ដោយ ក៏ឱសថអង់ទីប៊ីយ៉ូទិចទាំងនេះមិនរលាយក្នុងខ្លួនត្រី ឬវារីសត្វប្រកបដោយប្រសិទ្ធភាពមួយរយភាគរយនោះទេ ហើយភាគច្រើនកម្រិតឱសថប្រឆាំងមេរោគទាំងនេះបានក្លាយជាបញ្ហាកង្វល់ជាសកល។ ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (AMR) នៅក្នុងវារីវប្បកម្មបានកើតចេញពីការប្រើប្រាស់ឱសថវារីសត្វមិនបានត្រួតពិនិត្យបានល្អ ឬមិនអនុវត្តន៍តាមបច្ចេកបានត្រឹមត្រូវ ហើយនៅទីបំផុត សំណល់ឱសថទាំងនេះបាននិងកំពុងបង្កើនលទ្ធភាពចំពោះភាពស៊ាំនឹងឱសថប្រឆាំងមេរោគចូលទៅក្នុងបរិស្ថានទាំងមូល ហើយរួមផ្សំជាមួយការបម្រែបម្រួលអាកាសធាតុថែមទៀតនោះបានផ្ដល់ឱកាសបង្កើនហានិភ័យកាន់តែខ្ពស់ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស និងជីវៈចម្រុះនៅក្នុងប្រព័ន្ធទឹក ហើយនឹងបង្កឱ្យខាតបង់ដល់សេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ។ អាស្រ័យហេតុនេះ ដំណោះស្រាយប្រកបដោយនិរន្តរភាព ដើម្បីចូលរួមកាត់បន្ថយភាពស៊ាំនឹងឱសថប្រឆាំងមេរោគ គឺត្រូវតែគ្រប់គ្រង និងត្រួតពិនិត្យការប្រើប្រាស់ឱសថវារីសត្វក្នុងវារីវប្បកម្មឱ្យមានប្រសិទ្ធិភាព និងនិរន្តរភាព។

នៅក្នុងបណ្ដាប្រទេសអាស៊ីមួយចំនួន កសិដ្ឋានវារីវប្បកម្មត្រូវបានរៀបចំរួមបញ្ចូលគ្នាជាមួយការចិញ្ចឹមសត្វផ្សេងៗ អនុវត្តន៍ជាលក្ខណៈប្រពលវប្បកម្ម ដែលនាំឱ្យមានការបំពុលបរិស្ថាន និងសំណល់ឱសថនៅក្នុងអាហារដែលបង្កឱ្យមានភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (AMR) ជាច្រើន។ ការប្រើឱសថវារីសត្វខុសបច្ចេកទេសអាចបង្កផលប៉ះពាល់ជាអវិជ្ជមានលើសុវត្ថិភាពម្ហូបអាហារ បន្ទាប់មកប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្មជាសកល។ ឧទាហរណ៍ សំណល់ឱសថ Chloramphenicol ត្រូវបានបង្ហាញថា មានការព្រួយបារម្ភដល់សុខភាពមនុស្ស ហើយត្រូវបានហាមឃាត់ការប្រើឱសថប្រភេទនេះសម្រាប់ការធ្វើវារីវប្បកម្មជាទូទៅ។ កង្វល់ដូចបានរៀបរាប់ខាងលើ ត្រូវបាននាំមកនូវការវិវត្តន៍ និងការផ្លាស់ប្ដូរយ៉ាងខ្លាំងក្នុងការអភិវឌ្ឍនិងការប្រើឱសថវារីសត្វក្នុងខ្សែច្រវាក់ផលិតកម្មវារីវប្បកម្មដែលទាមទារឱ្យគោរពតាមគោលគោលការណ៍ណែនាំបច្ចេកទេសឱ្យបានត្រឹមត្រូវនិងខ្ជាប់ខ្ជួន។

គោលការណ៍ណែនាំបច្ចេកទេស សម្រាប់ការប្រើឱសថវារីសត្វក្នុងវារីវប្បកម្មនេះ ត្រូវបានរៀបចំឡើងដោយរដ្ឋបាលជលផល សហការជាមួយអង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម (UNIDO) ក្នុងគោលបំណងដើម្បីជំរុញឧត្តមានុវត្តន៍ (Best Practice) សម្រាប់ការប្រើឱសថវារីសត្វក្នុងវារីវប្បកម្ម និងកាត់បន្ថយភាពស៊ាំនឹងឱសថប្រឆាំងមេរោគជាអតិបរិមា ដោយផ្អែកលើអភិក្រមសុខភាពតែមួយ (One Health Approach) ដែលជាវិធីសាស្ត្ររួមបញ្ចូលគ្នា និងសហការពហុវិស័យ សម្រាប់សម្រេចបាននូវគោលបំណងរួម ក្នុងការលើកកម្ពស់សុខភាពរបស់មនុស្ស សត្វ និងប្រព័ន្ធអេកូឡូស៊ីមានភាពប្រសើរឡើង ព្រមទាំងទទួលស្គាល់អំពីទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងអាស្រ័យគ្នាទៅវិញទៅមករវាងសុខភាពរបស់មនុស្ស សត្វ រុក្ខជាតិ និងបរិស្ថានកាន់តែទូលំទូលាយ និងមានតុល្យភាពប្រកបដោយនិរន្តរភាព។

## ២. គោលបំណង

គោលការណ៍ណែនាំបច្ចេកទេសនេះ មានគោលបំណងគ្រប់គ្រង និងត្រួតពិនិត្យការប្រើប្រាស់ឱសថវារីសត្វក្នុងវារីវប្បកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើសុខដុមនីយកម្មជាមួយគោលការណ៍ណែនាំនិងស្តង់ដារនានារបស់គណៈកម្មាធិការកូដិចអន្តរជាតិ (Codex) និងក្រមសុខភាពសត្វរបស់អង្គការសុខភាពសត្វពិភពលោក (WOAH)។

## ៣. វិសាលភាព

គោលការណ៍ណែនាំនេះត្រូវបានរៀបចំឡើងក្នុងទិសដៅការកាត់បន្ថយនូវភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (អង់ទីប៊ីយ៉ូទិក) ក្នុងផលវារីវប្បកម្ម ជាអតិបរិមា ដើម្បីចូលរួមការពារសុខភាពសាធារណៈ និងជំរុញការនាំចេញផលផលិតផលជលផលកម្ពុជា ទៅកាន់ទីផ្សារអន្តរជាតិ។

គោលការណ៍ណែនាំនេះមានវិសាលភាពអនុវត្តចំពោះកសិដ្ឋានវារីវប្បកម្ម កន្លែងផលិត នាំចូល-នាំចេញ ធ្វើសន្និធិ វេចខ្ចប់ ចែកចាយ លក់ដុំនិងលក់រាយឱសថវារីសត្វ ក្នុងព្រះរាជាណាចក្រកម្ពុជា។

ចំពោះការតាមដាននិងត្រួតពិនិត្យសំណល់ឱសថវារីសត្វ ដែលត្រូវបានប្រើប្រាស់ក្នុងវារីវប្បកម្ម ត្រូវអនុវត្តតាមគោលការណ៍បច្ចេកទេសសម្រាប់កម្មវិធីជាតិតាមដាននិងត្រួតពិនិត្យសំណល់ឱសថវារីសត្វក្នុងវារីវប្បកម្ម ដែលកំណត់សេចក្តីសម្រេចរបស់រដ្ឋបាលជលផល។

## ៤. ការអនុញ្ញាតនិងហាមឃាត់ការប្រើឱសថវារីសត្វ

### ៤.១ ឱសថវារីសត្វដែលអនុញ្ញាតឱ្យប្រើក្នុងវារីវប្បកម្ម

ឱសថវារីសត្វត្រូវបានអនុញ្ញាតឱ្យប្រើក្នុងគោលបំណង សម្រាប់លើកកម្ពស់ផលិតភាព និងផលិតផល ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ចជាតិប្រកបដោយនិរន្តភាព ប៉ុន្តែការប្រើប្រាស់ឱសថវារីសត្វត្រូវស្ថិតក្នុងលក្ខណៈប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់របស់អ្នកប្រើប្រាស់ ដើម្បីកាត់បន្ថយហានិភ័យចំពោះការកើតមាន និងរីករាលដាលនៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគក្នុងបរិស្ថានទឹក។ ការប្រើប្រាស់ឱសថវារីសត្វក្នុងវារីវប្បកម្ម ត្រូវប្រព្រឹត្តទៅក្នុងកម្រិតអប្បបរមា ដោយអនុលោមតាមក្រមប្រតិបត្តិរបស់កូដិច និងគោលការណ៍អនុវត្តន៍វារីវប្បកម្មល្អ (GAqP)។

ការកំណត់សំណល់អតិបរមា (MRL) និងអនុសាស្ត្រគ្រប់គ្រងហានីភ័យរបស់អង្គការ FAO (RMR) ចំពោះផលិតផលនៃឱសថវារីសត្វ អ័រម៉ូន និងឱសថវារីសត្វជាក់លាក់ណាមួយ ដែលមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុង

វារីវប្បកម្មត្រូវយោងតាមគោលការណ៍ណែនាំរបស់កូដិច និងការណែនាំបច្ចេកទេស ស្តីពីការគ្រប់គ្រងហានិភ័យសម្រាប់សំណល់នៃឱសថវារីសត្វក្នុងផលិតកម្មវារីវប្បកម្ម។

ការប្រើប្រាស់ឱសថវារីសត្វក្នុងវារីវប្បកម្ម ត្រូវគោរពតាមការណែនាំ ស្តីពីដែនកំណត់សំណល់អតិបរិមា និងការគ្រប់គ្រងហានិភ័យលើភាពស៊ាំនឹងឱសថប្រឆាំងមេរោគ អ័រម៉ូន និងសារធាតុមួយចំនួន ដែលត្រូវបានប្រើប្រាស់ក្នុងវារីវប្បកម្ម។ MRL និង RMR ត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ ហើយកំណែចុងក្រោយបំផុតដែលអាចប្រើបានគួរតែត្រូវបានប្រើប្រាស់ជាការណែនាំស្តីពីដំណើរការនៃការអនុម័តឱសថវារីសត្វក្នុងវារីវប្បកម្មនៅកម្ពុជា។

ឱសថវារីសត្វដែលត្រូវបានចុះបញ្ជីទទួលការអនុញ្ញាតឱ្យប្រើក្នុងវារីវប្បកម្មមិនត្រូវប្រើជា "ឱសថ សម្រាប់ជំរុញការលូតលាស់" បានឡើយ។ ឱសថវារីសត្វដែលអនុញ្ញាតឱ្យប្រើប្រាស់ក្នុងវារីវប្បកម្មដែលអនុលោមតាមកម្រិតសំណល់អតិបរិមា (MRL) របស់កូដិច មានឈ្មោះដូចតារាងខាងក្រោម៖

តារាង ១. បញ្ជីឈ្មោះសារធាតុសកម្មនៃឱសថវារីសត្វ ឬសមាធាតុ និងកម្រិតអនុញ្ញាតប្រើប្រាស់

| ល.រ | ឈ្មោះ | កម្រិតសំណល់អតិបរិមា (MRL) |
|---|---|---|
| 1 | Oxytetracycline | 100 µg/kg |
| 2 | Amoxicillin | 50 µg/kg |
| 3 | Ampicillin | 50 µg/kg |
| 4 | Emamectin benzoate (anti-parasite) | 100 µg/kg |
| 5 | Ciprofloxacin | 0.5 µg/kg |
| 6 | Enrofloxacin | 0.5 µg/kg |
| 7 | Erythromycin | 200 µg/kg |
| 8 | Colistin | 150 µg/kg |
| 9 | Florfenicol | 1000 µg/kg |
| 10 | Sulphadiazine | 100 µg/kg |
| 11 | Sulphadimethoxine | 100 µg/kg |
| 12 | Sulphadimidine | 100 µg/kg |
| 13 | Sulfamethoxazole | 100 µg/kg |
| 14 | Tetracycline | 100 µg/kg |
| 15 | Doxycycline | 100 µg/kg |
| 16 | Trimethoprim | 50 µg/kg |

ការប្រើប្រាស់ឱសថប្រឆាំងមេរោគ (អង់ទីប៊ីយ៉ូទិក) ក្នុងវារីវប្បកម្ម មានភាពខុសគ្នាយ៉ាងខ្លាំងពីការប្រើប្រាស់ឱសថក្នុងវិស័យវេជ្ជសាស្ត្រសម្រាប់មនុស្ស និងវិស័យផលិតកម្មសត្វលើគោក។ អតិសុខុមប្រាណដែលពាក់ព័ន្ធនឹងជំងឺវារីសត្វក្នុងទឹក គឺមានភាពខុសគ្នាពីមេរោគដែលពាក់ព័ន្ធនឹងសត្វមានឈាមក្តៅ ដូច្នេះការអនុម័តការប្រើប្រាស់ត្រូវផ្អែកលើការវាយតម្លៃសម្រាប់តម្រូវការក្នុងផលិតកម្ម និងការវាយតម្លៃលើហានិភ័យចំពោះសុខភាពមនុស្ស។

## ៤.២ ឱសថវារីសត្វដែលហាមឃាត់ប្រើក្នុងវារីវប្បកម្ម

សារធាតុសកម្មនៃឱសថវារីសត្វ ឬសមាសធាតុគីមីដែលត្រូវបានហាមឃាត់ប្រើប្រាស់ក្នុងវារីវប្បកម្ម កន្លែងបង្កាត់-ភ្ញាស់ និងកន្លែងកែច្នៃ ក្នុងទំរង់ជាចំណីវារីសត្វ ការព្យាបាល សារធាតុលាងសម្អាត និងសារធាតុសម្លាប់មេរោគ ជាអាទិ៍ ដូចតារាងខាងក្រោម៖

តារាង ២. បញ្ជីឈ្មោះសារធាតុសកម្មនៃឱសថវារីសត្វ ឬសមាធាតុគីមីហាមឃាត់

| | |
|---|---|
| ១ | Aristolochia spp and by-products |
| ២ | Trifluralin |
| ៣ | Chloramphenicol |
| ៤ | Chloroform |
| ៥ | Chlorpromazine |
| ៦ | Colchicine |
| ៧ | Dapsone |
| ៨ | Dimetridazole |
| ៩ | Metronidazole |
| ១០ | Nitrofuran (AHD, AMOZ, AOZ, SEM) |
| ១១ | Ronidazole |
| ១២ | Dyes (Malachite Green and Leucomalachite Green, Crystal Violet and Leucocrystal Violet, Methylenblue, leuco Methylenblue) |
| ១៣ | Ipronidazole |
| ១៤ | Nitroimidazoles (HMMNI, RNZ, DMZ, IPZ, IPZ-OH, MNZ, MNZ-OH) |
| ១៥ | Clenbuterol |
| ១៦ | Diethylstilbestrol (DES) |
| ១៧ | Glycopeptides |
| ១៨ | Trichlorfon (Dipterex) |
| ១៩ | Gentian Violet (Crystal violet) |
| ២០ | Fluoroquinolones |
| ២១ | Methyltestosterone |
| ២២ | Ormetoprim |
| ២៣ | Medbenzazole |
| ២៤ | Ivermectin |
| ២៥ | Praziquantel |
| ២៦ | Plant protection products and biocide (Trichlorfon and Cypermethrin) |

## ៤.៣ ការប្រើឱសថវារីសត្វសម្រាប់ព្យាបាលវារីសត្វ

ការប្រើឱសថវារីសត្វក្នុងការព្យាបាលវារីសត្វ អាចប្រព្រឹត្តទៅបានលុះត្រាតែមានការឆ្លងរីករាលដាលនៃជំងឺណាមួយដែលត្រូវបានស៊ើបអង្កេតនិងវិនិច្ឆ័យដោយមន្ត្រីជំនាញវារីវប្បកម្ម ឬអ្នកជំនាញផ្នែកសុខភាពវារីសត្វតែប៉ុណ្ណោះ ហើយត្រូវអនុវត្តន៍តាមក្រមប្រតិបត្តរបស់ WOAH។

ការធ្វើរោគវិនិច្ឆ័យត្រូវអនុវត្តជាពីរកម្រិត៖ ការធ្វើរោគវិនិច្ឆ័យកម្រិតទី១ គឺត្រូវពិនិត្យលើរោគសញ្ញាវារីសត្វដែលមានជំងឺ និងការធ្វើរោគវិនិច្ឆ័យកម្រិតទី២ គឺត្រូវពិនិត្យដោយប្រើប្រាស់មីក្រូទស្សន៍លើស្នាមដំបៅ ឬការធ្វើតេស្តមីក្រូជីវសាស្ត្រ ឬធ្វើតេស្តផ្ទាល់ជាមួយឱសថប្រឆាំងមេរោគ ដោយប្រើស្តង់ដារវិធីសាស្ត្រវិភាគ ដូចជាស្តង់ដារ CLSI ជាអាទិ៍។

ការចម្លងជំងឺនៅក្នុងហ្វូងវារីសត្វក្នុងស្រះ ឬបែរ អាចមានសភាពលឿនណាស់ មិនដូចការចម្លងជំងឺនៅក្នុងហ្វូងសត្វលើគោកទេ។ ក្នុងករណីរកឃើញថា ត្រី ឬវារីសត្វមួយចំនួននៅក្នុងស្រះ ឬបែរមានជំងឺ មន្ត្រីអធិការកិច្ចវារីវប្បកម្មត្រូវផ្តល់បទបញ្ជាបច្ចេកទេសដល់វារីវប្បករ ឬម្ចាស់កសិដ្ឋានឱ្យធ្វើការព្យាបាលត្រី ឬវារីសត្វទាំងអស់ក្នុង

ស្រះ ឬបែរនោះ ដោយអនុញ្ញាតឱ្យប្រើវិធីសាស្ត្រ មេតាហ្វីឡាក់ស៊ីស (Metaphylaxis) ប្រសិនបើការធ្វើរោគវិនិច្ឆ័យបញ្ជាក់ថា ហានិភ័យនេះកើតឡើងដោយសារ បាក់តេរី ឬប៉ារ៉ាស៊ីត។

សារធាតុសកម្ម និងសមាសធាតុនៃឱសថប្រឆាំងមេរោគ សម្រាប់ផ្សំឱសថវារីសត្វ មិនត្រូវអនុញ្ញាឱ្យប្រើប្រាស់សម្រាប់ជំរុញការលូតលាស់ទាំងនៅក្នុងកន្លែងភ្ញាស់ ឬថែបំប៉នដំណាក់កាលវារីវប្បកម្មនោះទេ ប៉ុន្តែប្រភេទអ័រម៉ូនដែលប្រើប្រាស់សម្រាប់ការប្តូរភេទ ឬបង្កាត់ពូជអាចត្រូវបានអនុញ្ញាត ប្រសិនបើមានការចាំបាច់។

ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (អង់ទីប៊ីយ៉ូទិក) និងលើកកម្ពស់ការប្រើប្រាស់ឱសថវារីសត្វប្រកបដោយការទទួលខុសត្រូវ និងប្រុងប្រយ័ត្នខ្ពស់នៅក្នុងវារីវប្បកម្ម ឱសថវារីសត្វទាំងនោះមិនត្រូវបានអនុញ្ញាតឲ្យប្រើជាប្រចាំ ឬប្រើប្រាស់ក្នុងគោលបំណងផ្សេងដូចជា ប្រើប្រាស់សម្រាប់ធ្វើអនាម័យ បន្ថែមជាចំណីបំប៉ន ឬការងារដទៃសម្រាប់ជួយដល់ការគ្រប់គ្រងកសិដ្ឋាននោះទេ។

ការសិក្សាបែបវិទ្យាសាស្ត្រជាច្រើនបានបង្ហាញថា ការប្រើប្រាស់ឱសថប្រឆាំងមេរោគ (អង់ទីប៊ីយ៉ូទិក) ដើម្បីជំរុញការលូតលាស់ ឬបង្កើនទិន្នផល អាចនាំឱ្យមានការវិវត្តនៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

ឱសថប្រឆាំងមេរោគ ឬអង់ទីប៊ីយ៉ូទិកដែលប្រើប្រាស់សម្រាប់ការព្យាបាលមនុស្ស ត្រូវបានហាមឃាត់ប្រើប្រាស់សម្រាប់ការព្យាបាលវារីសត្វ ឬបន្ថែមទៅក្នុងចំណីវារីសត្វនោះឡើយ។ បញ្ជីថ្នាំអង់ទីយ៉ូទិក ឬក្រុមអង់ទីយ៉ូទិកដែលប្រើសម្រាប់ព្យាបាលជំងឺរបស់មនុស្ស សម្រាប់ការព្យាបាលជាក់លាក់ណាមួយគួរតែត្រូវបានពិនិត្យឱ្យបានទៀងទាត់ដោយផ្អែកលើភស្តុតាងវិទ្យាសាស្ត្រ ឬព័ត៌មានលេចឡើងថ្មីៗ។

## ៥. ការធ្វើពាណិជ្ជកម្ម

### ៥.១ ការធ្វើពាណិជ្ជកម្មឱសថវារីសត្វ

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងធ្វើពាណិជ្ជកម្ម ទិញ-លក់ ចែកចាយ ឬ/និង ធ្វើសន្និធិឱសថវារីសត្វគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

- រាល់ទិញ-លក់ ចែកចាយ និងធ្វើសន្និធិឱសថវារីសត្វគ្រប់ប្រភេទត្រូវមានការអនុញ្ញាតពីរដ្ឋបាលជលផល។
- រាល់ប្រភេទឱសថវារីសត្វ ត្រូវធ្វើការចុះបញ្ជីជាមុន ដោយអនុលោមតាមនីតិវិធីសម្រាប់ការចុះបញ្ជីឱសថវារីសត្វ ដែលកំណត់ដោយរដ្ឋបាលជលផល។
- រាល់ប្រភេទឱសថវារីសត្វ ដែលធ្វើចរាចរ ទិញ លក់ ចែកចាយ ឬ/និង ធ្វើសន្និធិសម្រាប់ការប្រើប្រាស់ក្នុងវារីវប្បកម្ម ត្រូវវេចខ្ចប់ឱ្យបានត្រឹមត្រូវ និងដាក់ស្លាកសញ្ញាឱ្យបានច្បាស់លាស់ជាភាសាខ្មែរនូវព័ត៌មានដូចខាងក្រោម៖

១. ឈ្មោះពាណិជ្ជកម្ម៖
២. ឈ្មោះទូទៅ៖
៣. ប្រសិទ្ធភាពឱសថវារីសត្វ៖
៤. ឈ្មោះ និងអាសយដ្ឋានរោងចក្រផលិត៖
៥. ឈ្មោះ និងអាសយដ្ឋានអ្នកនាំចូល៖
៦. កម្រិតនៃសារធាតុសកម្ម សមាសធាតុ និងសារធាតុបន្ថែម៖
៧. ប្រភេទគោលដៅ៖
៨. របៀបប្រើប្រាស់៖
៩. ដំបូន្មាន/បម្រាម៖
១០. សីតុណ្ហភាពរក្សាទុក៖
១១. លេខឡូត៍៖
១២. កាលបរិច្ឆេទផុតកំណត់៖

- ឱសថវារីសត្វដែលស្តុកនិងដាក់លក់ត្រូវធានាថា ឱសថវារីសត្វទាំងនោះត្រូវបានរក្សាទុកនៅសីតុណ្ហភាពត្រឹមត្រូវតាមការណែនាំសម្រាប់ផលិតផល ឬរោងចក្រ។
- ក្នុងករណី ឱសថវារីសត្វហួសកាលបរិច្ឆេទផុតកំណត់នៃការប្រើប្រាស់ ត្រូវបោះចោលប្រកបដោយសុវត្ថិភាពទៅតាមការកំណត់នៃប្រភេទកាកសំណល់ជីវវេជ្ជសាស្ត្រ ដើម្បីការពារផលប៉ះពាល់ជាអវិជ្ជមានដល់មនុស្ស និងបរិស្ថាន។
- របៀបប្រើឱសថវារីសត្វក្នុងវារីវប្បកម្មត្រូវផ្អែកលើការណែនាំជាលាយលក្ខណ៍អក្សរដែលកំណត់ដោយនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម។

## ៥.២ ចំណីសម្រាប់វារីសត្វ

- រាល់ទិញ លក់ និងចែកចាយចំណីវារីសត្វគ្រប់ប្រភេទត្រូវមានការអនុញ្ញាតពីរដ្ឋបាលជលផល។
- រាល់ចំណីវារីសត្វ និងគ្រឿងផ្សំចំណីវារីសត្វដែលនាំចូល ឬផលិតក្នុងស្រុក មិនត្រូវមានសមាសធាតុនៃឱសថវារីសត្វដែលហាមឃាត់ ឬមិនអនុញ្ញាត ដូចក្នុងតារាង ២. ដោយស្ថិតក្រោមស្លាកសញ្ញាពាណិជ្ជកម្មផលិតផលជាប្រភេទ "អ័រមនសម្រាប់ជំរុញការលូតលាស់" បានឡើយ។
- ក្រុមហ៊ុនផលិតចំណីសត្វនៅក្នុងប្រទេសកម្ពុជា ត្រូវធានានិងបញ្ជាក់អំពីអវត្តមាននៃសមាសធាតុឱសថវារីសត្វហាមឃាត់ ឬមិនអនុញ្ញាតដូចក្នុងតារាង ២. ក្នុងស្លាកសញ្ញាពាណិជ្ជកម្មផលិតផល។
- ចំណីលាយឱសថវារីសត្វនាំចូលអាចត្រូវបានអនុញ្ញាត តែក្នុងករណីពិសេសដែលមានការតម្រូវ ហើយរាល់ចំណីវារីសត្វនាំចូលត្រូវមានវិញ្ញាបនបត្របញ្ជាក់អំពីអវត្តមាននៃសមាសភាគនៃឱសថវារីសត្វហាមឃាត់ ឬមិនអនុញ្ញាតមានក្នុងតារាង ២.។
- ឱសថវារីសត្វដែលប្រើប្រាស់លាយផ្សំជាមួយចំណីគឺជាឱសថវារីសត្វដែលត្រូវបានចុះបញ្ជីនិងអនុញ្ញាតដោយរដ្ឋបាលជលផល សម្រាប់ប្រើក្នុងវារីវប្បកម្មតែប៉ុណ្ណោះ។

## ៥.៣ ការផ្សព្វផ្សាយពាណិជ្ជកម្មឱសថវារីសត្វ

- ការផ្សព្វផ្សាយពាណិជ្ជកម្មនូវផលិតផលឱសថវារីសត្វសម្រាប់ប្រើក្នុងវារីវប្បកម្ម អាចនាំឱ្យមានការប្រើហួសកម្រិតនិងប្រើប្រាស់ខុសបច្ចេកទេស ដូច្នេះរាល់ការផ្សព្វផ្សាយពាណិជ្ជកម្មអាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាតពីរដ្ឋបាលជលផល។

# ៦. ការត្រួតពិនិត្យសំណល់ឱសថវារីសត្វក្នុងវារីសត្វនាំចូល

- រាល់ការនាំចូលត្រីមេពូជ ឬកូនត្រីពូជ ត្រូវមានវិញ្ញាបនបត្របញ្ជាក់សុខភាពដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចេញដោយបញ្ជាក់អំពីសុខភាពវារីសត្វ និងអវត្តមាននៃមេរោគឆ្លងនានាយោងតាមបទបញ្ញត្តិជាតិ និងតាមគោលការណ៍ណែនាំរបស់អង្គការសុខភាពសត្វពិភពលោក។
- រាល់ការនាំចូលត្រីមេពូជ ឬកូនត្រីពូជ ត្រូវមានវិញ្ញាបនបត្របញ្ជាក់សុខភាព មុនចាប់ផ្តើមដឹកជញ្ជូននាំចូល ហើយត្រូវជូនដំណឹងដល់សមត្ថកិច្ចជំនាញនៃរដ្ឋបាលជលផល ដើម្បីពិនិត្យនិងយល់ព្រមលើឯកសារនាំចូលរួមមានវិញ្ញាបនបត្រសុខភាពជាមុនសិន មុននឹងទទួលការអនុញ្ញាតឱ្យនាំចូល។
- វិញ្ញាបនបត្រសុខភាពដែលបញ្ជាក់ពីសុខភាពវារីសត្វ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសចេញត្រូវធានាថា វារីសត្វនាំចូល (កូនពូជ ឬមេពូជ) គ្មានសំណល់ឱសថវារីសត្វហាមឃាត់។

- វារីសត្វនាំចូល (កូនពូជ ឬមេពូជ) ត្រូវធានាថា សុខភាពល្អ ឬ គ្មានជំងឺឆ្លងណាមួយ (Specific Pathogen Free)។

## ៧. សមត្ថកិច្ច និងការទទួលខុសត្រូវ

### ៧.១ អង្គភាពទទួលបន្ទុកមានសមត្ថកិច្ច

រដ្ឋបាលជលផល គឺជាអាជ្ញាធរមានសមត្ថកិច្ច ដែលមាននាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្មជាសេនាធិការ មានតួនាទីនិងភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រង និងត្រួតពិនិត្យការប្រើឱសថវារីសត្វ សារធាតុសកម្ម សមាសធាតុផ្សំ ដែលត្រូវបាននាំចេញ នាំចូល ផលិតលាយផ្សំ វេចខ្ចប់ជាថ្មី ធ្វើសន្និធិ ផ្គត់ផ្គង់ ចែកចាយ លក់ សម្រាប់ប្រើក្នុងវារីវប្បកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាចំពោះសុខមាលភាព ឬជីវិតរបស់មនុស្ស សត្វ វារីរុក្ខជាតិ និងការការពារបរិស្ថាន។

នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម ជាអង្គភាពទទួលបន្ទុកវារីវប្បកម្ម មានសិទ្ធណែនាំស្តីពីបច្ចេកទេសប្រើឱសថវារីសត្វក្នុងវារីវប្បកម្ម និងតាមដាន ត្រួតពិនិត្យលើឱសថវារីសត្វដែលត្រូវបានអនុញ្ញាត ហាមឃាត់ និងធ្វើបច្ចុប្បន្នភាពតាមការចាំបាច់។

### ៧.២ មន្ត្រីអធិការកិច្ចវារីវប្បកម្ម

មន្ត្រីអធិការកិច្ចវារីវប្បកម្ម គឺជាមន្ត្រីជំនាញវារីវប្បកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការគ្រប់គ្រង និងអធិការកិច្ចវារីវប្បកម្ម។ មន្ត្រីអធិការកិច្ចវារីវប្បកម្ម មានសិទ្ធិធ្វើអង្កេត ឬត្រួតពិនិត្យនៅកន្លែងបង្កាត់ភ្ញាស់ កន្លែងចិញ្ចឹម ទីតាំងកសិដ្ឋានវារីវប្បកម្ម ទីតាំងទិញ លក់ និងស្តុកទុកនៃឱសថវារីសត្វ គ្រប់ពេលវេលា ទោះបីដោយមានការជូនដំណឹងទុកជាមុន ឬគ្មានការជូនដំណឹងទុកជាមុន។

មន្ត្រីជំនាញវារីវប្បកម្ម ត្រូវបានតែងតាំងដោយសេចក្តីសម្រេចរបស់រដ្ឋបាលជលផល។

### ៧.៣ ការទទួលខុសត្រូវរបស់មន្ត្រីអធិការកិច្ចវារីវប្បកម្ម

មន្ត្រីអធិការកិច្ចវារីវប្បកម្ម មានតួនាទី និងភារកិច្ចក្នុងការត្រួតពិនិត្យ និងមានសិទ្ធិផ្តល់ការណែនាំបច្ចេកទេស ឬបញ្ហាបច្ចេកទេស សម្រាប់ការប្រើប្រាស់ឱសថវារីសត្វ។

មន្ត្រីអធិការកិច្ចវារីវប្បកម្ម ត្រូវអនុវត្តការត្រួតពិនិត្យនិងធ្វើរោគវិនិច្ឆ័យប្រកបដោយស្តង់ដារវិជ្ជាជីវៈខ្ពស់ ដើម្បីផ្តល់ការណែនាំបច្ចេកទេស សម្រាប់ប្រើប្រាស់ឱសថវារីសត្វឱ្យបានត្រឹមត្រូវ ដោយឈរលើមូលដ្ឋាននៃការពិចារណាលើសុខភាពសត្វ និងមិនផ្អែកលើការគិតគូរសេដ្ឋកិច្ចឡើយ។

### ៧.៤ ការទទួលខុសត្រូវរបស់វារីវប្បករ ឬម្ចាស់កសិដ្ឋានវារីវប្បកម្ម

វារីវប្បករ ឬម្ចាស់កសិដ្ឋានវារីវប្បកម្ម ត្រូវប្រើប្រាស់ឱសថវារីសត្វដែលទទួលបានការអនុញ្ញាតដោយរដ្ឋបាលជលផល សម្រាប់ជាឱសថព្យាបាល ឬមេតាហ្វីឡាក់ស៊ីស (Metaphylaxsis) តែប៉ុណ្ណោះ មិនត្រូវប្រើក្នុងគោលបំណងផ្សេងណាមួយឡើយ។

វារីវប្បករ ឬម្ចាស់កសិដ្ឋានវារីវប្បកម្ម ត្រូវប្រើប្រាស់ឱសថវារីសត្វដែលមានការវេចខ្ចប់បានត្រឹមត្រូវ មានស្លាកសញ្ញាពាណិជ្ជកម្មច្បាស់លាស់ និងមានការពន្យល់ណែនាំ ស្តីពីការរបៀបប្រើប្រាស់ ដូចមានចែងក្នុងចំណុច ៨.១ នៃគោលការណ៍ណែនាំបច្ចេកទេសនេះ។

ក្នុងករណីចាំបាច់ វារីវប្បករ ឬម្ចាស់កសិដ្ឋានវារីវប្បកម្ម អាចប្រើឱសថដែលត្រូវបានចុះបញ្ជី និងអនុញ្ញាតដោយរដ្ឋបាលជលផល ហើយត្រូវអនុវត្តការបញ្ឈប់ការប្រើមុនពេលប្រមូលផល តាមការពន្យល់ណែនាំបច្ចេកទេសលើស្លាកសញ្ញា ឬតាមការណែនាំរបស់មន្ត្រីជំនាញវារីវប្បកម្ម។

វារីវប្បករ ឬម្ចាស់កសិដ្ឋានវារីវប្បកម្ម ត្រូវរក្សាទុកដាក់ឱសថវារីសត្វឱ្យបានត្រឹមត្រូវ ហើយត្រូវបោះចោលសំបក ឬសំណល់នៃឱសថវារីសត្វដែលប្រើប្រាស់រួចក្នុងធុងសម្រាម ឬទីកន្លែងត្រឹមត្រូវ ជាសំណល់ជីវៈគ្រោះថ្នាក់។

វារីវប្បករ ឬម្ចាស់កសិដ្ឋានវារីវប្បកម្ម ត្រូវកត់ត្រារាល់ការប្រើប្រាស់ឱសថវារីសត្វក្នុងកសិដ្ឋានរបស់ខ្លួន និងត្រូវសហការល្អក្នុងផ្តល់នូវព័ត៌មានជូនទៅឱ្យនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល ក្នុងករណីមានការតម្រូវ។

វារីវប្បករ ឬម្ចាស់កសិដ្ឋានវារីវប្បកម្ម ត្រូវកត់ត្រារាល់ព័ត៌មាន ស្តីពីការប្រើឱសថវារីសត្វ និងជំងឺដែលត្រូវបានធ្វើរោគវិនិច្ឆ័យ កាលបរិច្ឆេទនៃការធ្វើរោគវិនិច្ឆ័យ កាលបរិច្ឆេទនៃវេជ្ជបញ្ជា កាលបរិច្ឆេទចាប់ផ្តើមនិងបញ្ចប់នៃការប្រើឱសថវារីសត្វ និងរយៈពេលប្រមូលផល។

វារីវប្បករ ឬម្ចាស់កសិដ្ឋានវារីវប្បកម្ម ត្រូវផ្តល់កិច្ចសហការជាមួយមន្ត្រីជំនាញវារីវប្បកម្ម ឬអ្នកពាក់ព័ន្ធឱ្យបានពេញលេញនិងមានប្រសិទ្ធិភាព។

-ចប់ -